# សេកសារិកា

KAMPOT CHILDREN'S LIBRARY
បណ្ណាល័យ. កុមារ



P-29 SEK SÂRIKÂ

N.53

KAMPUT CHILDREN'S LIBRARY
បណ្ណាល័យ. កុមារ

# រឿង

# សេកសារិកា

ចម្លងតាមសាស្ត្រស្លឹករឹត

ការផ្សាយរបស់

បណ្ណាគារ ក្រៃទេព

ផ្ទះលេខ ១៨៨ វិថីព្រះបាទសីហនុ

នឹងតូបលេខ ១៤៣ ទល់មុខចំណតរថយន្ត

ភ្នំពេញ

(រក្សាសិទ្ធិ)

ព.ស.២៥០៨ គ.ស.១៩៦៦

# សេកសារិកា

នេះនឹងថាថ្លែងចែងចារចង  ល្បើកល្បែងល្បិចល្បងជាកាព្យ
ប្រាំពីរពាក្យពិតគិតបួនឃ្លា  ចងជានិទានមានសេចក្ដី ។
កាលនោះមែនមានសេកសោមសត្វ  ព្រាត់ព្រាយស្រាយកាត់ការអ្វី ។
សម្បុរស្រស់ស្រៀវខៀវខ្ចីខ្ចី  សំដីពីរោះស្មោះសោះសា ។
ជាសេកព្រះមហោសថធីរ  បវររម្យរង្គមិថិលា
ឯស្ដេចសោយរាជ្យនៅនាមា  ឈ្មោះថាវិទេហកសក្សត្រថ្លៃ ។
ព្រះមហោសថហៅសោមបណ្ឌិត  ហៃហាជួនចិត្តជួនហឫទ័យ
អញ្ចាលចន់ប្រើឲ្យទៅក្រុងត្រៃ  ពិជ័យបញ្ចាលកជសេដ្ឋា ។
ឮថាព្រះមហាក្សត្រចុល្លណី  ទ្រង់ថ្វាយបុត្រីទ្រង់នាមា
បញ្ចាលចន្ទីពជពីកា  មកជាមហេសីម្ចាស់យើងកាយ ។
ថាមែនផ្ទួរព្រោះប្ដូរបម្ដេច  ឬក្លែកលកិច្ចគិតឧបាយ
ចរញ្ចោរសោមល្អួនដល់ស្រុកនាយ  ក្លែងក្លាយគិតកាប់សម្លាប់គ្នា ។
ឮថាព្រះមហាក្សត្រចុល្លណី  ចិញ្ចឹមនាងស្រីសត្វសារិកា
ទុកទ្រង់ប្រើបត្រៃទេនក្រឡា  ចិន្តាគតការជាសុខុម ។

ពីរនាក់និងព្រាហ្មណ៍នាមឈ្មោះថា អាចារ្យកែវវត្តព្រាហ្មណ៍ជាធំ
នៅក្នុងក្រឡាខែនបន្ទំ នេះសមសារិកាដឹងមិនខាន ៗ
បានទៅលួងលោមនាងសារិកា ឲ្យបានជាតិជាគូរួមឋាន
សាកសួរកិច្ចការឲ្យដឹងដាន ចាប់វិលវិធីថ្កានណាសេកណា ៗ
ថាហើយទើបគន្ធព្រះមហោសថ ប្រាជ្ញាមោះមុតដូចខ័នថ្មា
ប្រទានចេកទុំនិងផ្កា ឲ្យសេកកោក្តាលាជទឹកឃ្មុំ ៗ
សេកសោមចឹកស៊ីអស់ចំណី ពិសេសពីសម្ផ្គតពោះធំ
ចាំអស់បណ្តាំផ្តាំសុខុម កាន់ស្វាបចង្កំហើយលាទៅ ៗ
ចូលកាលច្ចុនព្រៃស្រោងស្របឆាត ហើរកាត់ក្នុងជ្រោះជ្រោលជ្រៅ
ដល់ក្រុងបញ្ចាលស្តេចគង់នៅ មើលទៅប្រាសាទស្អាតពណ្ណរាយ ៗ
កំពែងក្លោងទ្វារសឹងមណ្ឌប ទ្វារផ្សារមានគ្រប់សែនសប្បាយ
សត្វសេកត្រេកអរមើលពីឆ្ងាយ អរអស់ក្នុងកាយឥតគណនា ៗ
ទំលើកំពូលប្រាង្គប្រាសាទ ព្រះបាទចុល្លណីឃើញគិតថា
គួរគេញុបទុំសព្វកាល ឲ្យនាងសារិកាកែវបានស្តាប់ ៗ
ឲ្យដឹងថាអញបានមកដល់ មន្ទីរមណ្ឌលដោយសួរសព្ទ
យល់ថាឱនក្បែរក្រងំស្តាប់ ចេញពីទ្រុងចាប់មកខាងក្រៅ ៗ

គិតហើយសេកសោមសើចហើយស្រែកសួរសព្ទសម្រែកក្រាកក្រអៅ

ពីកោះរៀយរាបសុភាពទៅ　　ហាក់ដូចនឹងហៅស្រីសារិកា ។

សារិកាកែវឮសួរសព្ទសត្វ　　ពីកោះពេចក្តាត់ផតគណនា

ព្រឺព្រួចគ្រលួចក្នុងចិន្តា　　នឹងទូចគាត្នាទៅពុំបាន ។

ផ្កាដោយជាស្រីស្រើបតណ្ហា　　មិនមានប្រុសណាទៅក្នុងឋាន

ឮសួរសម្លេងព្រឺព្រួចប្រាណ　　ស្រើបស្រួលក្សេមក្សាន្តក្នុងកាយា ។

ចេញពីទ្រុងមាសរំពេចខ្លី　　ដោយក្តីស្រឡាញ់ពេញស្នេហា

ញីរខ្លួនអង្រួនអស់សិរសា　　ងៀងឈ្ងង់ទ្រោមើលមកក្រៅ ។

ក្រឡេកឃើញសេករូបល្អស្អាត　　ទំលើប្រាសាទមាសបង្អួចនៅ

ផ្ញើហាក់ដាហើរដើរតិចទៅ　　ទំលើចង្អួចតុបនា ។

សើចហើយស្រដីមើលទៅមេឃ　　ឲ្យសេកក្រឡេកមើលគ្នា

ផ្កាដោយស្រឡាញ់សេកណាស់សា　　ភាសាក្រអៅលាន់ឮសាយ ។

សេកសោមឮសួរសព្ទភាសា　　សារិកាកែវស្តីមកពីឆ្ងាយ

ងៀងឈ្ងង់មើលហើយសើចក្អាកក្អាយ　　កៃក្រាយធ្វើហើរដើរតិចទៅៗ

ស្រដីនឹងសត្វសារិកាកាន　　ហៃកែវកល្យាណរូបល្អញីល្អ

ស្ងួនអើយបងបានមកជួបនៅ　　ជួនពៅពាលពេញរូបផែតឆាយ ។

ប្អូនអើយបងស្ទុះបងស្ទើរគេ សព្វប្រែកជ្រលងដែនដីឆ្ងាយ
ខេត្តតូចធំផងទាំងឡាយ មិនឃើញរូបកាយដូចប្អូនស្ងួន ៗ
ស្ងួននួនទេវីនៃល្អបម្រុក ជាស្រីល្អឯកសមសក្តិស្ងួន
ល្អស្អាតបំពុះនិងផងខ្លួន នាងនួនប្អូនល្អម្តេចសម្បាយ ៗ
បងបានជួបជួននឹងមាសមេ ជាពៀរពុំព្រួតពីក្រៅនាយ
សាងសូមផងគ្នាណានាងអើយ ទើបបានមកជួបក្រៃលក្ខណ៍ ៗ
ប្អូនស្ងួននួននាងអាសូរចិត្ត ករុណិតបងចុះណាសារិកា
ប្តូស្រីហាមាត់មកបរោ ទឹមបងគិតពីណាពុំស៊ា ៗ
បំណាច់បំណាំងបងមកដល់ កក់បាយទេសល់ណាប្អូនក្ញ
ព្រលឹតមើលមុខប្អូនកាលណា ធ្លូចបានកេក្តាបាយថ្លែកហើយ ៗ
ប្អូនអើយហៃប្អូនស្ងួនសម្លាញ់ កុំស្ងួនគ្នាន់ក្ញាញ់ក្នុងចិត្តឡើយ
កាសូមេគបងណានាងអើយ កុំធ្វើតោះគេយណានាងណា ៗ
បងបានជួបជួនប្អូនប្រិមប្រិយ៍ ដូចបានជួបស្រីហាំនស្ងួតា
កៃកុំអស់ឯកធ្វើព្រាញក ស្ងួនក្ញាករុណាកែចិត្តបង ៗ
បំណាច់បំណាំងបងកេជួន មកជួបនឹងស្ងួននាងនួនល្អង
ប្តូហាមាត់ស្តីមកកាន់បង តែម្តងសឹមស្រីនាងស្ងៀមចុះ ៗ

ទំថ្វីមិនស្តីនៅទ្រមឹង សញ្ជប់សញ្ជឹងដាក់ចំពុះ
មៀនមើលប្រែខ្លួនផ្ញើអេះអុះ ឬមួយប្អូនទាស់ចិត្តត្រង់ណា ។
សារិកាកែវស្តាប់សោមបណ្ឌិត ស្រដីលួងចិត្តលួងពោធា
បែរធៀនមៀនមើលទៅហើយថា អ្នកមកពីណាមករកក្ញី ។
ទំលើកពូលប្រាង្គប្រាសាទ នៃអង្គព្រះបាទក្សត្របុល្យណ៍
មិនមានក្រែងខ្លាចព្រះបារមី ក្សត្រក្សត្តិយបតីមានចេស្តា ។
ហ៊ានហើរចូលមកដល់ក្នុងវាំង ស្រែកយំពួនខ្លាំងក្រៃសោះសា
បើស្តេចទ្រង់ជ្រាបជាក់កាលណា យល់ថានឹងក្ស័យជន្មជាតិ ។
មិនដឹងទេឬស្តេចមានបុណ្យ បណ្តាសស់ជនសឹងក្រែងរ៉ឹង
យើងជាសារិកាកែវនៅទិត្យ ទិនព្រះបុត្រស្តេចកេក្យ ។
មិនមានសត្វណាចូលមកដល់ មន្ទីរមណ្ឌលរាជសីមា
ស្រដីបែបង់ត្រង់ស្រីណា អ្នកឯងហានក្លាចូលមកដល់ ។
យើងមិនស្រើស្រើបស្រាលអ្នកផ្ការ ស្រើបដោយពណ្ណាគិតក្លាយខ្វល់
ព្រៃកសន្ទឹកប្រុសមកដល់ សំដែងឲ្យយល់អង្គគ្នា ។
អ្នកឯងកុំមកស្រដីលេង បែបង់ជាល្បែងតាមតែថា
ចរចេញទៅក្រៅពីវាំងណា ទំពាយើងទូលស្តេចមិនខាន ។

អ្នកទើបស្លាប់ខ្លួនបងអាសារ ឥតការព្រោះចិត្តគិតក្លាហាន
ទើបកើតទោសទាល់ដល់ខ្លួនប្រាណ មិនបានឃើញមុខឪពុកម្ដាយ ៗ
ថាហើយសារិកាកែវបែរបៀន ឈ្លងឈៀងមៀងមើលសេកពីឆ្ងាយ
ធ្វើជាបែរមុខសើចក្អាកក្អាយ ក្លែងក្លាយដោយកលកិច្ចមាយា ៗ
សេកសោមលោមថាកែវព្រលឹង ប្អូនគួរកុំខឹងណា នាងណា
បណ្ដេញបងថ្វីនាងសារិកា បងមិនយាត្រាទៅទៀតឡើយ ៗ
បងបានឃើញប្អូនល្អចំណាប់ សូវស្លាប់ក្នុងរាងនេះនាងអើយ
មិនបងឈានទៅណាទៀតឡើយ ប្រកើយប្រកៀកស្លាប់ពឹងប្អូន ៗ
សូវស្លាប់ទើបស្រីសារិកាគាប់ កុំឲ្យអកតខ្លួនសោះសូន្យ
បំណាច់ចំណាស់បងបានជួប មកជួបនឹងប្អូនតែកល្យាណ ៗ
សូវស្លាប់ចាប់ជាតិវិញជាថ្មី ក្រែងតែបានស្រីស្រស់សារិកា
ជាគូគំនាប់នៅនឹងគ្នា លុះត្រាតែក្ស័យជន្មជីវិត ៗ
ថ្ងៃអើយថ្ងៃថ្មើមដើមខ្លួន សូមនួនរំពឹងផ្ចាំងគិត
កុំគួរកុំគាប់ធ្វើតាមចិត្ត មាសមិត្តពិនិត្យឲ្យថែប្អូន ៗ
បងមិនជួបសេកឯទៀតទេ រួមសេនឹងមេហើយហោលសួន
ឲ្យប្អូនអកីតស្លាប់ដល់ខ្លួន ស្រីនួននាងដេកតែម្នាក់ឯង ៗ

ប្រសិនបើឯងបានស្ងួនក្ងា ជាតិជាគូគ្រងបងមិនលែង
ចរចេញចោលស្ងួនឲ្យចំឡែង កុំប្អូនគិតក្រែងចោលស្ងួនក្ងា ៗ
សារិកាកែវស្ដាប់ពាក្យសេកសោម ស្រដីល្អងលោមចង់ឃាត់
ស៊ើបហើយស្រដីទៅវិញថា អនិច្ចាអន្និតមិនចេញទៅ ៗ
ទំតែស្រដីមកប៉ោចៗ ដូចខ្លាចចោរមានមកពីក្រៅ
នរណាស្នេហ៍ស្និទ្ធជិតនិងទៅ ស្ដាប់ក្រមមកនៅឋាននេះណា ៗ
យើងជាសារិកានៅក្នុងកំង ស្ដេចតាំងទុកជាក្អែកក្រា
សេកឯងហើរមកពីឋានណា ហៅហាំងតុះពារបួលមកស្ដី ៗ
ចូរប្រាប់នាមស្រុកនាមនៃខ្លួន ឲ្យជាក់ឲ្យដួនអាចសេចក្ដី
ហើរមកប្រាថ្នាក់លការអ្វី ចូរស្ដីឲ្យត្រង់កុំលាក់ឡើយ ៗ
សេកសោមស្ដាប់ពាក្យស្រីសារិកា ចែងចេះចរចាស់ផ្ទង់ឆ្លើយ
សួរស្រុកសួរឈ្មោះដូច្នេះហើយ សេកអាត់តស្បើយក្នុងចិន្ដា ៗ
គិតថាបើអញប្រាប់តាមត្រង់ ថាមកពីក្រុងត្រៃសីមា
ស្រុកឈ្មោះនគរមិថិលា យល់ជាសារិកាគិតសង្ស័យ ៗ
ថាអញមកស៊ើបសួរពត៌មាន ឲ្យបានដឹងការកិច្ចដៃ
គួរកុំប្រាប់ត្រង់គិតតែកែ កុហកវៀនវែរទៅទៀតជា ៗ

គិតហើយសេកសោមសើចស្រដី ហៅស្រីសារិកាកែវកល្យាណ
បងនៅឯផ្កាផសីមា ឈ្មោះថាហ្នឹងសេកសោមបណ្ឌិត ៗ
បងជាមហាគលិតព្រះមហាក្សត្រ ឈ្មោះសេរីវ័ត្តកជមានឫទ្ធិ
ជាខ្ញុំព្រះអង្គទ្រង់គាណិត ព្រះបាទបពិត្រស្ដេចរក្សា ៗ
ប្រទានប្រពន្ធមួយឲ្យបង រូបល្អឥតគង់ដូចទេព្ដា
ឈ្មោះនាងសារិកាកែវកល្យាណ ល្អដូចស្មួនការខ្មួនបួបងន ៗ
ឲ្យនៅទ្រង់មាសមួយមូលគ្នា មិនឲ្យឃ្លាតឃ្លាចកនៃន
ប្រាប់គ្រែក្រឡាខែនគម្លង ស្ដេចតែងព្រោសប្រើតែសញ្ញថ្ងៃ ៗ
បងនៅរួមសេរួមរ៉ាសនា ទឹងនាងសារិកាផើមពេញផ្ទៃ
បងនាំប្រពន្ធហើរវិលវៃ មកលេងមកទំទៀបចមគ្នា ៗ
នៅនាកនហាលក្សត្រគណ្ណកយ ជាទីសប្បាយសព្វទ័ព
វេលាព្រឹកព្រោងស្វាងស្វិយោ ហាលអស់ការាជឲ្យកក់ក្ដៅ ៗ
មួយថ្ងៃមានសត្វកូនកំណាច ជាសត្វខ្ជួចគាចដូរតទៀវ
ហើរឆោចទន្ទួបលឿនស្ទុះស្ទៅ សំដៅកនហាលទំផែលទំ ៗ
ឯបងជាប្រុសហើរឆាប់ក្រៃ ចូលផល់ក្ដនស្មៃនខែនបន្ទំ
ប្រពន្ធបងសោកគ្នាពោះធំ ទំប្រឹងហើរទៅពុំរួចឡើយ ៗ

ខ្វែងឆាបយកទៅជាអាហារ　ស្លាប់ខ្លួនគ្នាណាខានអើយ
បងកើតទុក្ខពុំក្រើមិនស្បើយ　ប្អូនអើយនឹកឡើងមិនចង់ស្តី ។
កាំងតែជាទុក្ខទៅក្នុងទ្រូង　សុំកុតសុំកុងកើតទុក្ខខឹ
និរាសព្រួសចាំងទំចំណើ　កិច្ចការអ្វី ៗ គ្មានទឹកនា ។
ស្តាំងស្តមជាខ្លួនតែងជាទុក្ខ　ក្រៀមក្រំចាំងមុខចុកទុក
ទឹងដេកគ្មានសុខ ៗ គ្រង់ណា　ភ្លេចគាល់មហាក្សត្រជាធិបតី ។
ប្រពន្ធបងស្លាប់ទៅសឹងព្រាំ　កាន់ទុក្ខទៅចាំជាងឆ្នាំបី
ជាសេកតោះម៉ាយទេណាស្រី　ស្រីញីអ្វី ៗ គ្មានជិតជល់ ។
ជូនបួលដូវទៃកក្តិក　ព្រៃតែលន្ទឹកសព្ទសូរខ្យល់
បក់មកត្រជាក់អស់កាយកល　ខ្វាយខ្វល់ល្ហៃល្ហទុក្ខចិន្តា ។
នឹកដល់ប្រពន្ធបងដែលស្លាប់　តែងធ្លាប់ដេកជិតកិតនឹងគ្នា
ឥឡូវខ្យល់បក់មកនោះ　កំព្រាកំព្រោះតែម្នាក់ឯង ។
បងធ្លាប់តែដេកជិតប្រពន្ធ　បំពែបំអន់បកប្រឡែង
ឥឡូវឃ្លាតបាត់ព្រាត់ចម្លែង　សត្វក្អែកឆាបយកទៅហើយ ។
ម្ចាស់បងទ្រង់ជ្រាបបងកើតទុក្ខ　អផ្សុកក្នុងខ្លួនមិនមានស្បើយ
បន្ទូលត្រាស់ថាហៃសេកអើយ　កុំជាទុក្ខឡើយណាសេកណា ។

អញ្ញគេថាក្សត្រចុល្លណី　ចិញ្ចឹមនាងស្រីសត្វសារិកា
ខ្លួនខ្មៅស្រអែមឯកកាយា　ក្សត្រាស្តេចសព្វព្រះហឫទ័យ ។
ចូរបាហិចហើរទៅនគរ　ឧត្តរបញ្ចាលរាជក្រុងក្រៃ
សួរនាងសារិកាឲ្យដឹងន័យ　ជាចិត្តអាល័យជួបបួលគ្នា ។
ហើយបាវិលវិញមកឆាប់ក៏　មកប្រាប់ឲ្យអញដឹងគប្បការ
អញនឹងរៀបអស់បណ្ណាការ　ដណ្តឹងឲ្យបានជាប្រពន្ធ ។
ចង់ឮម្ចាស់បងប្រាប់ដូច្នោះ　ព្រឺព្រួចក្នុងពោះគ្រាន់ស្រាកស្រន់
ស៊ីលាជទឹកឃ្មុំផ្អែមផ្គន់　កាន់ស្វាបគិតគន់បង្គំលា ។
ហិចហើរកាត់ល់ព្រៃព្រឹងជ្រៅ　សំដៅបូរីរាជសេមា
មិនបានឈរឈប់ស្របកាយា　ប្រឹងហើរណាស់ណាឲ្យបានដល់ ។
ដោយអើយដោយឆាយដូចផ្កាយព្រឹក　ចង់ទឹកភ្នែកថ្លៃពេកពិតសល់
សូមស្ងួនខ្លួននាងគិតឲ្យយល់　គាស្បូរមកដល់ចិត្តបងក៏ ។
ចំណាប់ចំណងបងស្នេហ៍ស្នេះ　លាលះបុរីរាជសេមា
បងមកយកប្អូនជាសង្សារ　ស្រីស្រស់សារិកាកុំអាលឯក ។
កុំគាលខានខំប្រឹងសំឡុក　ធ្វើភ្នែកមក់ៗ ស្តីប្រកែក
មិនព្រមថ្ងៃនេះរេះហាស្អែក　ជាកែជំពោះល្ហោះទឹងចង ។

អាសូរចិត្តបងបន់ប្រាថ្នា សារិកាកែវអើយឆ្លើយមកហោង
កុំស្ងៀមកុំស្ងាត់បាត់សាសង មាសបងមន្ទិលចិត្តគ្រង់ណា ៗ
បងនឹងនិយាយឲ្យស្រីស្តាប់ សាសព្ទសព្វពាក្យពេជន៍ម្តេចម្តា
កុំឲ្យប្អូនមាសមានសង្កា មិនជឿចិត្តបងណាមាសមេត្រ ៗ
បងមិនស្រដីវែកសាកង ករហូតប្រាជ្ញព្រាងបញ្ចូលចិត្ត
ឲ្យតែប្អូនស្ងួនទទួលមិត្ត ម្លោះសំឡាលស្និទ្ធចាកហោលគ្នា ៗ
សារិកាកែវស្តាប់សេកសាសង ប្រាប់តាមទំនងនៃគាថា
ក្នុងចិត្តគាណិតសេកណាសា ហេតុតែជាស្រីការក្តីខ្លាយ ៗ
សើចហើយស្រដីនៃសាសង អ្នកបងសេកសោមបេះនិយាយ
ដំណើរទំនងរៀងរៀងកាយ ថ្លៃបាយឲ្យប្អូនបានជងជានៗ
ប្អូនសោតជាស្រីតើជឿងអ្វី ព្វតែសំដីជឿម្តេចបាន
ពាក្យប្រុសវែងភរក្លួតអួតប្រាណ កែ្លងក្លាយទានមកបន់ស្រី ៗ
អ្នកជាសត្វសេកសោមបណ្ឌិត ខុសគេទន្សាពិតពេញគប្រិយ
ប្អូនជាសារិកាកែវត្លួវត្រី ម្លោះសំមេត្រីនិងសេកសត្វ ៗ
បើសេកនឹងសេកសមណាសំណា ពូជពង្សវង្សាទើបគួរគ្នាត់
សារិកាកែវគួរប្រតិព័ទ្ធ និងសត្វសារិកាទើបសមគ្នា ៗ

ឥឡូវខ្ញុំអ្នកជាសេកសោម រូបតោមខៀវស្រស់អស់អង្គ
ប្អូនខ្មៅស្រគមផ្លែកពណ៌ផ្កា បេះអើកាលណាទឹងសមស្ងួន ។
នេះហើយអ្នកអើយអ្នកសត្វសេក ក្រឡេកមើលទៅពណ៌ដោយខ្លួន
តាំងឈ្មោះខុសត្រាណាអ្នកស្ងួន មិនខ្មាសប្អូនមិនខ្លួនទៀត ។
ជាបើខុសត្រាតែបន្តិច ប្អូនគិតតែងតែអធ្យាស្រ័យ
ខុសត្រាច្រើនណាស់ណាអ្នកថ្លៃ ប្អូនអធ្យាស្រ័យបានត្រង់ណា ។
ប្រសិនបើកើតជាកូនចៅ រាំងឹងកាត់ទៅតាំងអ្នកណា
កាត់ទៅជាសេកឬសារិកា ប្អូនខ្មាសណាស់សាណាអ្នកថ្លៃ ។
សេកអើយប្អូនគន់គិតត្រង់ត្រប់ ថប់ហើយវិងថប់ពន់ពេកក្រៃ
មន្ទិលក្នុងចិត្តគិតសង្ស័យ ទឹងគិតកែខៃទៅទណា ។
ខុសឃើញតែទមានបន្ទោះ ចំពោះទំនោះអញទៅជា
កុំឲ្យមានពាក្យគេនិន្ទា ឲ្យបាសង្កាណាអ្នកថ្លៃ ។
ត្បិតប្អូនជាស្រីនៅក្នុងវាំង ស្ដេចតាំងជាមេក្នុងក្រុងក្រៃ
បណ្ដាអស់ស្នំក្រមសាវវៃ នូវមុខមន្ត្រីពជះយោធា ។
សិនតែកប់គាទគិតផតខ្មាច អំណាចតែខ្លួនតែគ្រប់គ្នា
ថាប្អូនស្ងួនត្រង់អស់ភរិយា មិនស្រើបស្រាលជាស្រីគ្រប់លក្ខណ៍ ។

ឥឡូវនេះកូនមកមានប្ដី សេកសោមអប្រិយ៍តូចពាបសក្តិ
ពាបពង្សវង្សជាតិជួរអាបលក្ខណ៍ ញាតិញាក់ខ្លួនសោះសារិការអើយ ។
អូនឮសពាក្យនេះណាអ្នកថ្លៃ អូនគិតស្រយណាស់អ្នកអើយ
គិតទៅជាមុនឲ្យរ៉ាហើយ កាលអើយកាលណោះសមគិតទៀតៗ
អ្នកអើយអ្នកសេកសោមបណ្ឌិត អ្នកគិតឲ្យមួនជួនបង្អៀត
អ្នកកុំគិតយូរឆ្ងូរពេលមៀត គិតទៀតគិតទៅឲ្យឃើញឆ្ងាយៗ
សេកសោមស្ដាប់ពាក្យស្រីសារិកា តែងពេះបរហាការកើតឆ្ងាយ
បែមុខមើលហើយសេចក្ដាកក្ដាយ ថាប្អូនតោមឆាយស្ដីពីរោះៗ
គិតគួចការកើតគេខ្នា មន្ទិលខាំងខាការគ្រង់នោះ
ត្រូវណាស់ណាស្ងួនពេញចំពោះ ផូញោះបង់ទន់ទន់យាយប្រាប់ៗ
ចូរសើសារិកានាងជំងាន ជីនដោយបេទិតានពីរពេជ្រសក់
ទុកជាសំដីនៃសណ្ដាប់ បង្អឹងថ្លែងប្រាប់គ្រាន់កសាន្តៗ
ថ្ងៃមួយសម្ដេចព្រះនរនាថ ចេញទៅប្រពាតចំខ្យាន
ឃើញនាងជម្ពូកែវតលក្សណ ក្បូត្រខ្សាន្តស្ដេចសព្វព្រះហឫទ័យ ៗ
វនាងជំពូវត្ដីនោះ ពូជពន្សវង្សឈ្មោះតូចពាចព្រៃ
ចយលោកត្រកូលពំប្រពៃ ឥតអ្នកដទៃគេកាប់គាន ៗ

ទើបអស់កិន្នរនាំគ្នាទៅ ដល់ទីលំនៅឥសីណា
យំហើយពិតព្រះតុទ្ធដិកា សូមតានលោកតាជួយប្រោសប្រាណ
និម្ដុលោកតាទៅបានឆាប់ សម្លាប់ពីងពាងកាចឲ្យបាន
ពាស៊ីកិន្នរក្នុងសមសាន្ត មិនបានខាតខានដល់មួយថ្ងៃ ។
ឥសីស្ដាប់ពាក្យអស់កិន្នរ លួងលោមឥន្ទ្រពន់ពេកក្រៃ
ខ្ញាល់ហើយគំហក់ទៅញាវិវៃ ថាហៃហ្វូងកិន្នរពាំងឡាយ ។
អញជាឥសីសាងសីលសុទ្ធ ចំរើនព្រឹទ្ធព័ត្រក្នុងកលកាយ
សម្លាប់សត្វមេចបានងាយ ។ ចៀសចេញឲ្យឆ្ងាយកុំមកស៊ុំ ។
ឯអស់កិន្នរផងពាំងឡាយ ចៀសចេញប្រញាយខ្វាចឥសី
ពុំហ៊ានទទឹងស្ដីថាអ្វី ។ វិលវឹងទៅទីឋានគុហា ។
ទើបអស់កិន្នរផងមកជុំ មកជួយជំនុំព្រមទាំងគ្នា
ថាយើងទៅពីឥសីណា យល់ថាលោកតាពុំប្រណី ។
នាងវត្តត្រីស្រីកិន្នរ រូបរាងល្អះល្អមខ្មប្រឹមប្រិយ៍
បដូចព្រះចន្ទពេញបូណ៌មី ជាស្រីប្រកបនូវលក្ខណា ។
យើងទីងបាត់ចែងតែងផ្គួផាប់ ប្រដាប់គ្រប់គ្រឿងពណ៌គស្ដ្រា
នាំទៅប្រគេនដល់លោកតា យល់ថាទីងព្រមប្រោសប្រណី ។

ផ្ចិតហស់ស្រឡាញ់តែក្រមុំ រូបឆោមល្អសមព្រហ្មចារី
បានឃើញរូបឆោមនេត្រ្តី យល់ថាឥសីស្រក់ទឹកមាត់ ៗ
ថាហើយកិន្នរផងទាំងឡាយ តែងកាយរត្តិស្រីរូបរត្ន
ពាក់អាវលាបម្សៅផ្ទូរផងផាត់ ស្លៀកទៀងដាយស្បាត់ស្បៃបៃតង ៗ
ស៊ុស្អាដិតមាត់មុខបំប្រែម ញញឹមហើយស្ដីសើចផ្គួន ៗ
ជនឫក្សពេលាពេលហើយហោង នាំគ្នាត្រសន់ទៅមុន្នី ៗ
ឲ្យនេត្រត្តិស្រីកិន្នរ រូបល្អដើរមុខតាមមាគ៌ា
កិន្នរដើរក្រោយបណ្ដោយគ្នា លុះត្រាតែទៅដល់ឥសី ៗ
ទើបអស់កិន្នរផែនបង្គំ ឥសីឧត្ដមមានបារមី
ប្រគេនកិន្នរនេត្រ្តី ចូលជាសិស្សថ្វៃនៃលោកតា ៗ
សូមទានឲ្យលោកតាទៅទាប់ សម្លាប់ពន្ធពាន់ដូចប្រាថ្នា
ឥសីស្រដីសើចហើយថា ត្រង់នេះទុកអារឲ្យគាបក្ក ៗ
ថាហើយលាផ្នួសចេញជាមួន កំកាន់ដំបងព្រេចខ្មី
មើលឃើញពន្ធពាន់ដេកទៅដី ឥសីវាយសម្លាប់ផ្ងៀស្រចាន់ ៗ
ហើយរើសវិន្តក្តានបានកុដិ រួមរស់មេត្រីស្រីមានភ័ន
រួមបរមសុខសប់សពាន់ ឧដ់នាន់វិត្តស្រីកិន្នរ ៗ

ហៃស្រីសារិកាកែវមាសបង់ នេះហេតុនិទានមានប្រះណា
មនុស្សលោកកាលណោះយកកំឡូក បានជាគូគ្រងគ្នាថាអ្វី ។
ឥឡូវប្អូនស្រីជាសារិកា ចង់ជាសត្វសេកទេណាស្រី
ជាសត្វទន់សត្វស្លូតចិត្ត រួមសោមត្រីមូលមួយគ្នា ។
ម្ដេចប្អូនរកពុំប្រកែក ស្រដីជជែកទៅផលណា
ទៅមុខៗគ្មានគេៗនិន្ទា ផ្សងតពន្យវាទីព្រាត់គ្នាហើយ ។
សារិកាកែវស្ដាប់សោមបណ្ឌិត និយាយព្រេងព្រឹទ្ធពីដើមឡើយ
កុំចិត្តគណ៌តសេកគ្មានស្បើយ សើចហើយស្រដីទៅវិញថា ។
ហៃសេកអ្នកឯងស្ដីពីរោះ ស្ដីចំពោះគសព៌ា
យកពីព្រេងព្រឹទ្ធមកឧបមា ប្អូនឥតបើជាណាអ្នកថ្មី ។
តែប្អូនទៅគិតចិត្តសង្កា ផ្សើតអង្គព្រះមហាក្សត្រជៀវស្ងៃ
ម្ចាស់ប្អូនស្រឡាញ់ប្អូនពេកក្រៃ ក្សត្រថ្ងៃពុំទាន់ប្រាប់កិច្ចការ ។
ជាប្អូនទំនួកស្មោះស្មើចិត្ត អាណិតស្រឡាញ់ពេញស្នេហា
ប្រសិនស្ដេចប្រាប់សព្វកាលណា យល់នឹងថាព្រាតក្រៃមិនខាន ។
មានតែអ្នកវៃទៅម្ចាស់អ្នក ក្រាបទូលឲ្យជាក់ជាពិតមាន
ជាប្អូនមន្ទិលណាសក្ដិប្រាណ ឲ្យម្ចាស់អ្នកបានប្រាប់កិច្ចការ ។

ឲ្យស្តេចរៀបភ័ស្តុគាតុ ។ ពិសេសពិស័ត្រកាលជា
នូវអស់គ្រប់គ្រឿងបណ្ណាការ មកជាជង្វាយថ្វាយជូនជាប់ៗ
ជណ្ដើរយកប្អូនជាភរិយា គេឃើញគ្រប់គ្នាទើបត្រូវច្បាប់
បើម្ចាស់ប្អូនផ្សែសមគួរគាប់ ប្អូនស្រាប់តែដោយមហាក្សត្រា
ប្អូនជាជើងក្រោយដោយជើងខុំ ពុំហ៊ានដាក់ទុកខ្លួនឡើយណា
ប្អូនតាមតែម្ចាស់ប្អូនមេត្តា ប្រទានផ្កាប្អូនក៏យក ៗ
សេកសោមបណ្ឌិតឆ្លើយទៅថា ហៃស្រីសារិកាកែវពន្លក
បំណាច់បំណាក់បងហើយមក បងនឹងយកប្អូនជាសង្សារ ៗ
ផ្លូវប្អូនស្ងួនទៅប្រកែក ស្រដីដែតកើតសង្កា
ថាឲ្យបងវិលទៅភាគ ទូលមហាក្សត្រាជាម្ចាស់បងៗ
ឲ្យស្តេចរៀបអស់បណ្ណាការ នូវអស់ភ័ស្តុភាមកតម្គង
មកថ្វាយម្ចាស់ប្អូនឯអាយផង ជណ្ដើរទទួលជាភរិយា ៗ
បើស្តេចម្ចាស់បងនៅឯកាយ រៀបជាជង្វាយថ្វាយហើយណា
ម្ចាស់ប្អូនពុំទ្រង់ព្រះមេត្តា ឲ្យស្រីសារិកាកែវមកបង ៗ
ជង្វាយនោះខ្ញុំបានគាសា ផគការទៅទេណាទូលល្អង
ចុះគេចាត់ចោលក្នុងទឹកហោង មាសបង ៗ សូមទីលាគណា

ហេតុតែកម្មបងពីបុព្វេ បានឃើញទុរមេហើយឃ្លាតគ្នា

ថាហើយសោកសោមដោមសោភា ហើរដើរម្នាទៅទៀបខាន ៗ

ចាំទៀបផតស្រីសារិកា ស្តីថាតៃហមាសមានរូបកង

តៃមុខមកតាយ ណាខ្ពួននាង បងអស់សំណាងនឹងប្អូនហើយ។

បងស្តីដូចម្ដេចប្អូនមិនស្តាប់ បងសួរដូចម្ដេចប្អូនមិនឆ្លើយ

តើកម្មបងទេណានាងអើយ ម៉្លេះហើយបងសូមនឹងលាទៅ ៗ

តែស្មឹងសុះគេគួរស្រកបង ឲ្យល្អបែកផាំងប្អូនពៅ

កុំឲ្យតក់ក្តីខ្លួនណាហៅ ប្អូនប្អូននាងនៅឲ្យសប្បាយ ៗ

តម្ក្រាលខ្លួនបងជាតក់ស្លុត មិនមានតរក្ខតក្ដីគលកាយ

ប្អូនពុំពេញចិត្តជននៀយណាយ នៅណានាងអើយនៅត្រៀងជា ៗ

ថាហើយសោកសោមទុនចំពុះ ទុនក្បាលផាក់ចុះទៀបសារិកា

ធ្វើហាក់ជាដើរហោរម្នា សារិកាឃើញហើយទឹកស្លួបផាប់

សោកសោមសើចហើយស្តីទៅថា តទិញ្ញាចិត្តស្រីចំណាច

ខ្លួនបងមានធ្វើក្តីពុំគាប់ ប្អូនស្រីចិត្តជាប់ខ្លួនអន្ទាក់បង ៗ

ខ្លួនបងនេះមានបើខុសក្តី កំប្អូនប្រឹមប្រើស្រីខ្លួនល្អង

មកចឹកមកតាមខ្លួនសញ្ញាបង សារិកាតែវិនៃលេងបងទៅ ៗ

សារិកាស្ដាប់សេកសោមបណ្ឌិត អៀនអន់ក្នុងចិត្តស្ងៀមស្ងាត់នៅ

មិនហ៊ានទទឹងស្ដីឆ្លើយទៅ ក្រញ៉ូក្រាបឱត្យនៅទីនោះណា ៗ

សេកសោមយល់ស្រីសារិកាគាប់ ស្ងៀមស្ងាត់ពុំសង់សព្វកំពា

ចំពុះចឹកជាប់ក្បាលសារិកា ធាតាជាន់ស្ងាតសារិកាខ្ញី ៗ

ប្រែប្រុណាប្រែប្រឹងត្រីកោមា រួមសេតណ្ហាជាសេរី

រង់រែតស្រឡាញ់ពេញបេតី នាងស្រីសារិកាកែវពេលព្រាណ ៗ

សេកក្មួយទៅស្រុកមិថិលា សារិកាក្មួយគាល់មហាក្សត្រក្សត្តិ

សេកក្មួយព្រះមហោសថប្រោសប្រាណ សារិកាក្មួយហ៊ានទ្រង់មាសខ្ទី

ផ្សាដោយសេកសោមជាកម្លោះ សារិកាកែវនោះព្រហ្មចារី

សក្ដិសមមនោរម្យបតី ឥតក្ដីរង្គៀមានឃ្លើសឃ្លង ៗ

សារិកានិងសេកទាំងទៀតគ្នា ចរចានិយាយសើចផ្ដន់ៗ

បែរមុខមើលគ្នាហើយផ្ញៀនផ្ញួន សាសន៍ទាំងពីរពេញស្នេហា ៗ

ទើបស្រីសារិកាបៀតទៀបទំ លាបលាយទឹកឃ្មុំផា ៗ

ឲ្យសេកស៊ីហើយស្ដីទៅថា អញ្ជើញពិសាឲ្យសប្បាយ ៗ

សារិកានិងសេកស៊ីចំណី ពិសេសពិសីឆ្អែតក្នុងកាយ

និយាយសើចលេងជាសប្បាយ រួចកាយទាំងពីរពេញបេតី ៗ

ទើបស្រីសារិកាប្រាប់សេកសោម ហៃអ្នកមានឆោមឆើតប្រិមប្រិយ
យើងទើបបានគ្នាជាប្អូនថ្មី ពាក្យស្អីក៏គាប់ឥតមន្ទិល ។
អ្នកកុំយកមកសោកសួរលេង ប្អូនគិតក្រែងកើតរឿងកំពល់
ពាក្យស្អីជាគាប់មានមន្ទិល សូមសេកអ្នកយល់យកមកថ្លឹង ។
សេកសោមស្រដីវៃទៅថា សារិកាកែវអើយគន់គិតក្រែង
យើងនឹងឃ្លាតឃ្លាព្រាត់ប្រាសត្រី បងមិនថ្វាយផងទេណាស្រី ។
រសៀលទន់ទាបព្រះសុរិយា សេកនឹងសារិកាសុំចំណី
លុះយប់ព្រលប់ចូលរាត្រី សេកដេកនឹងស្រីស្រស់សារិកា ។
នែបនិត្យផ្ដិតខ្លួននឹងខ្លួនហើយ កៀកកើយកាន់កិតស្និទ្ធស្នេហា
ស្លាបនឹងចំពុះនោះផ្ទឹមគ្នា រួមរស់តណ្ហាជាសុខសាន្ត ។
លុះព្រឹកស្វាងជ្រះស្រឡះមេឃ សារិកានិងសេកបរបេញប្រាន
មកទំទៀបគ្នាជាសុខសាន្ត សម្រាកសម្រាន្តតែសព្វថ្ងៃ ។
សេកសោមរួមរស់ពីរកាយា នឹងស្រីសារិកាស្រស់ល្អក្រៃ
ចាប់ចិត្តកាន់គិតគន្លងអាល័យ យូរថ្ងៃមិនអស់ចិត្តស្នេហា ។
យូរថ្ងៃទើបសេកសោមបណ្ឌិត គន់គិតក្នុងចិត្តនៃគាថា
ជាអញ្ជើញមកសួរស្រីសារិកា ឲ្យដឹងកិច្ចការការពិតមាន ។

ទឹនគាលវិលវឹងទៅចំហុត ទូលព្រះមហាសេទ្បើងថាខ
គិតហើយសេតសើចស្ដីទៅភ្កាន ថាហៃកល្យាណស្រីសារិកាៗ
បងឮពាក្យពេចន៍ទៅតែផ្ដាស អស់ក្រស្ដនិយាយលេងនឹងគ្នា
ថាស្ដេចបក្សីណីបារមីក្លា ទឹងថ្វាយធីតាជាមហេសី ៗ
ទៅព្រះមហាក្សត្រិទេសកស ពាក្យឮតែផ្ដាសគេស្រដី
មែនពិតដូច្នោះប្អូនស្រី ប្ដីលេងសើចជាសប្បាយ ៗ
សារិកាតែស្ដាប់យាត់ទៅថា អ្នកកុំបាណាអ្នកថ្លៃ
ប្អូនបានប្រាប់អ្នកមកពីឆ្ងាយ កុំឲ្យនិយាយពាក្យពុំជា ៗ
ពាក្យនេះពុំគាប់អពមង្គល កុំអ្នកយោគយល់យកមកថា
មិនពាក្យមង្គលទេអ្នកណា អ្នកទឹងសួរជាដំណើថ្មី ៗ
សេតសោមសើចហើយស្ដីទៅថា ហៃស្រីសារិកាវែកពីសី
ពាក្យជាមង្គលទេណាស្រី ប្ដីស្ដីប្រាប់មកបងណាចក៏ ៗ
គាណិតបងពុះថ្ងៃថ្មីមួយ កុំឲ្យបងព្រួយសួរច្រើនគ្រា
សារិកាគណិតសេកសង្សារ ស្ដីថាផុនណាសណាអ្នកថ្លៃ ៗ
ប៉ុន្តែពាល់ហើយលើសង្សារ ស្មោះស្មើចិត្តដូចហាម្ចទយ
បើអស់អ្នកផង់គេក្រោធក្រៃ ប្អូនកើតសង្ស័យប្រាប់មិនបានៗ

ម្ចាស់ប្អូនទ្រង់គិតការនេះជ្រៅ  មិនឲ្យអ្នកក្រៅគេដឹងដាន
ក្រែងឮដំណឹងខ្ចរខ្ចាយសាយសព្វឋាន  មិនបានសម្រេចដូចចិន្តា ។
ស្តេចគិតបញ្ឆោតទៅមហោសថ  ជាបុត្រកុម្ពីកមានប្រាជ្ញា
បញ្ឆោតវិទេសកស្តេចក្សត្រា  ថាថ្វាយធីតាថាទេពី ។
នាមឈ្មោះបញ្ចាលចន្ទីថ្លៃ  រូបរាងល្អិតល្អក់ក្រៃប្រិមប្រិយ
ឲ្យចូលទៅក្នុងវេជ្ជបុរី  ទទួលបុត្រីកនធីតា ។
ស្តេចចាប់យកខ្លួនទៅទាំងរស់  សម្លាប់ឲ្យអស់ជន្មជីវ៉
ទាំងមុខមន្ត្រីស្តេចយោធា  កុំឲ្យសល់គ្នាដល់មួយនាក់ ។
ការនេះដឹងតែប្អូនម្នាក់ឯង  ប្អូនយកមកថ្លែងប្រាប់ឲ្យជាក់
ប្អូនប្រាប់នេះជាពាក្យលួចលាក់  បើអ្នកបានដឹងកុំស្តីឡើយ ។
ក្រែងគេស្អប់អ្នកផងគេដឹងដាន  ដឹងអស់ពត៌មានការណ៍នេះហើយ
ជ្រាបដល់ព្រះមហាក្សត្រព្រាណព្រើយ  អ្នកអើយសមខ្លួននឹងមរណា ។
សេតសោមបានស្តាប់អស់សាសព្វ  សារិការកែវប្រាប់សព្វពា
មានចិត្តត្រេកអរឥតឧបមា  ដោយដឹងកិច្ចការផងទាំងឡាយ ។
សើចហើយស្រដីវៃទៅថា  ហៃស្រីសារិកាកែវនាមឆាយ
ឯអស់កិច្ចការផងទាំងឡាយ  បងមិនប្រាប់ប្រាយអ្នកដទៃ

ប្រាប់ម្ដេចឲ្យខូចផល់ផ្ញើមថ្ងៃ  ផ្ដើមសាច់ខ្លួនខ្លួនល្អតរៃ
ទុកស្រីជីវិតបង់សព្វថ្ងៃ  ប្អូនកុំសង្ស័យក្នុងចិន្ដា ។
ពាក្យនេះជាពាក្យមន្ដលេខ  កុំប្អូនមាសមេគិតសង្កា
ត្រង់យើងព្រាត់ខ្លាត់ចេញពីគ្នា  មិនដូចបោះណាទេតាមឆាយ ។
សារិកាស្ដាប់សេកសាសន៍ស្ដី  រំភើរតបតសើបក្អាកក្អាយ
ប្រែប្រាណប្រែសេកហើយនិយាយ  ជាសុខសប្បាយទាំងពីរប្រាណ ។
ទើបសេកគន់គិតក្នុងចិត្តថា  អញបានសារិកាកែវរួមថាន
ប្រាយប្រាប់កជាការពិតមាន  ល្មមវិលវិញក្ដានថានមិថិលា ។
ប្រាប់ព្រះមហាសេដ្ឋឲ្យទ្រង់ជ្រាប  អស់គាថផងបរសព្វកិច្ចការ
គិតហើយសេកប្រាប់ទៅសារិកា  ហៃកែវកល្យាណ៍ភក្ត្រច្រឹមប្រិយ ។
បងសូមលាប្អូនកែវកល្យាណ  វិលក្ដានទៅកាន់ពង់បុរី
ក្រាបទូលម្ចាស់បងលើសិរសី  ឲ្យព្រះបក្រីជ្រាបពត៌មាន ។
ថាបងបានរួមសេ់មេត្រី  និងស្រីសារិកាកែវកល្យាណ
ឲ្យស្ដេចរៀបអស់គ្រឿងប្រទាន  មកថ្វាយព្យុគ្រង្សន្តជាម្ចាស់ប្អូន ។
ស្ដេចនឹងរៀបអស់បណ្ណាការ  នូវរបស់គ័ស្ដុកាយកមកជូន
ឲ្យត្រូវតាមច្បាប់កុំឲ្យសូន្យ  ដំរៀបនិងប្អូនទៀតផង ។

កុំឲ្យប្អូនស្ងួនខ្លួនសង្ស័យ បងទៅបីថ្ងៃវិលវិញវៃ
ក្រាបទូលឲ្យដឹងដើមសេចក្ដី កុំស្រីសារិកាកែវគិតបង ។
ហាក់ដូចបងបានខ្លួនប្អូនទៅ បានហើយចោលចោលចេញជាម្ដង
លោមលាទៅស្រុកខ្លួនវិញហោង កុំឲ្យអ្នកផងគេនិន្ទា ។
បើបងមិនទៅក្រាបទូលស្ដេច ឲ្យដឹងអស់អាថិពាក្យកិច្ចការ
ក្រែងកើតទោសខុសដល់គាត់ ក្រុបព្រះរ៉ាតាមពាក្យគ្រក្សាន្ត ។
បូស្រីនាងនៅក្នុងប្រាសាទ រក្សាឲ្យស្អាតខ្លួនកល្យាណ
ក្រែងសេកសារិកាណាបងបាន ទឹងមានមន្ទិលដល់ខ្លួនស្រី ។
នៅចាំទំរាំបងមកដល់ កុំបីប្អូនស្ងួនខ្លួនភិតភ័យ
តែបងទៅដល់វិលវិញថ្មី ចិត្តនៅស្នេហ៍ស្រីស្ងួនខ្លួនល្អង ។
បងស្រឡាញ់ពិតមិត្តពាលពៅ ចិត្តនៅចាំចងឥតសៅហ្មង
ពោះចាំងព្រលឹងខ្លួនអញបង ឲ្យនៅគ្រប់គ្រងរក្សាស្រី ។
សារិកាកែវល្អាប់សោមបណ្ឌិត ថ្លែតផ្អកក្នុងទ្រូងមិនចេញស្ដី
ក្រៀមក្រំចាំងមុខកើតទុក្ខថ្មី ប្រឹងតែទំស្ដីទៅវិញថា ។
ហៃអ្នកសេកសោមបណ្ឌិតអើយ អ្នកអើយអ្នកទៅចោលប្អូនក្ដា
ចោលប្អូនតែឯងឲ្យកំព្រា ប្អូនដេករងាតែម្នាក់ឯង ។

ធ្លាប់ដេកធ្លាប់ដើរហើរជិតគ្នា  ទំទឹមបរបាចកក្រឡែង
ធ្លាប់ស៊ីចំណីជុំស្អាតនេត  តកម្ពុតព្រៃឲ្យឃ្លាតឃ្លា ។
អ្នកទៅដោយផ្លូវប្រុងប្រយ័ត្ន  ក្រែងសត្វប្រមង់ខ្វិនស្រាកណា
ក្អែកក្អាក់ប្រមាថតុះពាធា  ឃើញអ្នកឥតគ្នាក់មើលងាយ ។
អ្នកអើយអ្នកទៅកុំនៅយូរ  កាស្ងូរទ្រូងប្អូននៅឯនាយ
ថាហើយស្រក់ទឹកភ្នែកហូរខ្លួយ  តក់ស្លុយសោកសោមសង្សារថ្មី ។
ហើយស្រីសារិកាយំបណ្ដើរ  រៀបឲ្យដំណើរសេកជាប្ដី
ឲ្យស៊ីបេកទុំទំចំណី  ពិសេសពិសីគ្រាកាលជា ។
ហើយថាពិសាឲ្យឆ្អែតឆ្អល់  ក្រែងឲ្យល់ហាបតាមមាគ៌ា
ជៀតទៅម្នាក់ឯងគ្មានគូគា  ឈប់ថាត់ទរណាទងមើលអ្នក ។
សេកសោមករុណាស្រីសារិកា  ស្រក់ទឹកនេត្រាហូរសស្រាក់
ស្ដីថាហៃពៅចៅចមកត្រ្គ  កុំស្រីអួលគក់អន់ចិន្តា ។
បងទៅមិនយូរទេណាស្រី  ទង់វិលវិញមកដាបក
ថាហើយសេកសោមតោមសោកា  ទំទៀបទឹមគ្នាទងសារិកា ។
សិរសាផែបទន្សជិតជិតគ្នា  ព្រោះជាប់ក្ដួចព្រួបស្នេហា
ខំប្រឹងទទះស្លាបគាគា  មើលមុខសារិកាហើយហើរទៅ ។

ចេញពីពន់ព្រៃត្រែជ័យ ទន់ដើរទន់ដៃតាំងស្ទាបក្បូរ
ទំប្រឹងសន្ទឹងស្ទាបហើយទៅ សំពៅពលវែងសន្ធឹមឆ្ងាយ ៗ
លះនោះបក្សិបក្ខនោះសង្វេគ កាណិតខ្លួនពេកឯកអង្គកាយ
ពលវែងជួបបន្រ្ទាត់វែងឆ្ងាយ ពីកាយសារិកាកែវពិសី ៗ
ត្រែងត្រស់ផុះដោយពលគុម្ពោត ដូចខ្លួនបងសោកគ្រាប់កេស្រី
គុម្ពោតកំពុងផែបេតី កម្មអ៊ុំកឡៀបនឃ្លាតឆ្ងាយ ៗ
គន់ទៅត្រពាំងទឹកពេញប្រៀប ឈូកសផុះត្រៀបរៀបលេចសាយ
ផ្កាឈូកដូចនោមនាងឆើតឆាយ កេសរក្លែបក្លាយដូចកូនស្រី ៗ
មើលផងទំនងព្រៃស្រងាត់ ព្រៃដូចបងព្រាត់ពៅពិសី
សុក្រំក្រំចិត្តគិតតិចអ៊ី ខ្លួនស្រីដូចស្រីស្រស់ឆោមឆាយ ៗ
មើលភ្នំធំនែវនព្រែក មើលទឹករលករលោមសាយ
មើលដី ៗផុះវៃធំឆ្ងាយ មើលមេឃខ្ពស់ឆ្ងាយដូចឆ្ងាយស្រី ៗ
មើលដើមត្របែកមែកទន្ទឹន ដូចបងបែរបែកស្រស់ប្រិមប្រិយ៍
ដើមទៀបដូចបងទំទឹមស្រី ដើមឃ្មុំអ៊ុមកឃ្លាតឃ្លា ៗ
នាងខ្លួនដូចបងនៅនែបនិត្យ ដើមគគីរគិតស្តីលោមលា
ដើមកេតដូចបងកេបួនក្សា ពុំព្រាត់ទ្រង់ស្រីឆើតឆោមឆាយ ៗ

ឈើតាលដូចបងទំនៃបនិត្យ　ដើមកោបូលកិតជិតនិយាយ
ដើមស្មីដូចស្ត្រីគ្រគ្រូមកាយ　ដើមក្រោយបងក្រទិនរំរះគិត ។
មើលផ្កាកំភ្លឹងព្រៃនេះហើយ　ផ្កាអើយផ្កាសល្អពេញចិត្ត
កំភ្លឹងកុំភ្លេចអ្នកមិត្ត　ស្រឡិតស្រឡាញ់ពេញចិត្តប្រែ ។
បងគន់ ៗ មើលផ្កាចម្ប៉ា　ចំពើបបានគ្នាណាអ្នកថ្លៃ
ចំប៉ីចំពោះចិត្តអាល័យ　ផ្កាសោតសង្ស័យសង្សារថ្មី ។
ផ្កាកំផ្លៀមរំដេងខ្ទិតគ្រប់　ស្រឡិតស្រឡប់ចប់ស្មារតី
ម្លិះរួត ៗ រឹតតែបេតី　ម្លិះលា ៗ ស្រីទៅស្រុកហើយ ។
ទុផ្កាម្នាមម្និលក្រែង　ក្រែងប្អូនស្នេហ៍ស្និទ្ធទឹងដឹងអើយ
ក្តាំងអារអាបងមិនមានស្បើយ　ផ្កាអើយផ្កាទៅពោលសង្សារ ។
មើលផ្កាវបេកវជួលចិត្ត .　លន់តែ ៗ គិតផ្អិតទុក
ស្វាកែតដូចកែវកិតកាយា　សេកទំទមគ្នាសុំសប្បាយ ។
បងគន់មើលទឹក ៗ ស្រះស្រី　ស្មុខសីងកែត្រីក្រមក្រុះក្រោយ
ព្រៃកែនជនខ្ទូងជ្ជួនសណ្តាយ　ទាំងហាយទាំងហាត់លោតជិញគ្នា ។
ត្រីព្រួលដូចបងប្រូងប្រយ័ត្ន　ក្រែងប្អូនប្រាសព្រោតពីទុក
ព្រលូងប្រលៃងលេងលោមលោ　ត្រីប្រាដូចបងព្រាសជោមធាយ ។

បងគន់មើលទៅផ្លូវស្រុក សារិកាកែវទំយំព្រួសាយ
កៀនគួឈ្មោលញីស៊ីសប្បាយ បរហាររួសរាយទៅទីនគ្នា ។
សេកសោមកៀនគួចាំងឈ្មោលញី រកស៊ីស្រុករកនគួរ
កេងកងក្រួយងក្រួបក្រសារ ខ្ទាខ្ទះស្លាបហើរហ្វូង ។
ឥស់សត្វសឹងជួបជុំគួរ បងឃ្លាតសារិកាកែវនួនល្អង
កំព្រាព្រាត់គូបេញជាម្ដង រំដេរដោយផងផែនអញ ។
អ្នកអើយអ្នកសត្វហើរកាត់ទៅ សំដៅលំនៅទីឋានណា
កៀនគួឈ្មោលញីស៊ីត្រៀបត្រា មិនមានឃ្លាតឃ្លាងលំមួយឡើយ។
តែខ្លួនអញឯងតែងកំព្រា ព្រាត់ស្រីសារិកាកែវបេញហើយ
គ្មានគូទឹងគេជាពីឡើយ កម្មអើយកម្មគួរឲ្យអនិច្ចា ។
បងតយគន់មើលឥស់សត្វម្រឹគ កៀនគួគឹកក្នុងអញ
ឈ្មោលញីស៊ីដោយផងមាគ៌ា តែបងកំព្រាគ្មានគូឡើយ ។
បងមើលទៅព្រៃឡៅស្រទុំ ព្រៃជ្រុំព្រៃជ្រៅឆ្ងាយណាស់ហើយ
ស្រងូតស្រងាត់ឆ្ងាយបាត់ត្រើយ ប្អូនអើយស្រងស់ក្នុងកាយា ។
មើលត្រើយតួចផងពេញពាស ដេរដាសដោយផងផ្កែអញ
កំពូលកំពស់ស្មើមេឃា ស្រងូតកាយាស្រងស់កាយ ។

មើលមេឃា មីស្រែចំមក ពពកសស្កុះវែងឆ្ងាយ
ឈោងចាប់មិនដល់ខ្យល់ផាត់ផាយ ឆ្ងាយហើយរឹងឆ្ងាយសល់សែនយោជន៍ ។
បងទំដើរធ្វើផងព្រៃជ្រៅ កាវើយាសយំស្នូរសត្វតូច
ឮស្នូរល្ហើយៗឆ្ងាយណរខ្ទោច លន្ទង់ត្រពោចឯកគត្តិកាយ ។
ប្រសិនបើស្រីស្រស់សារិកា មកទីនិរៀមពីសមសប្បាយ
ស៊ីផ្លែផ្នូសព្រៃសព្រីងស្វាយ ក្រពាយផកពាយផកពាទុំ ។
បងស៊ីតែឯងចម្បែងព្រៃ ភ្លេចថ្ងៃសារិកាកែវក្រមុំ
មិនបានមាសមកមូលជួបជុំ មិនសមបើស៊ីតែឯងឡើយ ។
បងឃើញផ្លែឈើអស់ទាំងនោះ មិនចង់ស៊ីសោះណាប្អូនអើយ
ទន់ស្លាបទន់ជើងអស់ទៅហើយ ល្ហិតល្ហើយក្នុងខ្លួនមួនមាំក្រៃ
ក្នុងចិត្តគានណិតស្រីសារិកា ព្រួយព្រៃចិន្តាគិតគាល័យ
ឃើញសត្វសារិកាទៀតដទៃ ស្រមៃដូចស្រីហើរតាមបង ។
ផល់បែរប្រែខ្លួនមើលទៅជាក់ មិនមានខ្លួនអ្នកមាសជាម្តង
រន្ធត់ស្លុតចិត្តពេកកន្លង ខំហើរដោយផងដែនគង្គា ។
ពេលរសៀលទន្ទាបល្ងាចថ្ងៃ សេកហើរជ្រៀវប្រែងរហាស់
កន្លងរលងព្រៃព្រឹក្សា ដល់ដែនមិថិលាកដបុរ ។

ចូលទៅបង្គំព្រះមហោសថ    ជាម្ចុផក្កុជុំគមានសួស្តី
ក្រាបទូលពីកិច្ចការស៊ើប    ដែលស្រីសារិកាប្រាប់ពិតមានៗ
ព្រះមហោសថស្តាប់សោមបណ្ឌិត    ត្រេកអរក្នុងចិត្តពន់ប្រមាណ
យកលាជទឹកឃ្មុំប្រទាន    ឲ្យសត្វសេកបានបរិភោគ ៗ
សត្វសេកស៊ីអស់ទាំងចំណី    ពិសេសពិសីគ្រាកាលជា
ទឹកដើមទៅដល់ស្រីសារិកា    ធ្លាប់ស៊ីផ្សំគ្នាជាប្រក្រតី ៗ
ឥឡូវមកស៊ីតែម្នាក់ឯង    ចម្លែងក្នុងចិត្តគិតគិតគូ
បងស៊ីទាំងទុក្ខទេណាស្រី    ព្រោះឃ្លាតចំណីព្រោសប្រពានៗ
ឯចិត្តបងនេះត្រង់បាយទឹក    មិននឹកស៊ីសោះណាកល្យាណ
តាំងពីព្រាត់ប្រាសចាកចេញឋាន    បងមានតែទុក្ខបុកទុក ៗ
រសៀលសូរ្យសែនសាយគាទិត្យ    នឹកបិទបាំងចែងសុរិយា
សេកដេកក្នុងទ្រុងមាសរចនា    ម្នាក់ឯងកំព្រាសោរសល់ ៗ
ទុអញធ្លាប់ដេកទន់សារិកា    ឥឡូវអោរដោយសារខ្យល់
គ្មានគ្នាដេកជិតគិតកាលកល    កម្មអើយមកផ្តល់ឲ្យវេទនា ៗ
លុះព្រឹកមើលមេឃមីស្រទំ    ព្រះសូរ្យផ្គត់ក្រទុភ
ផ្គរពីទិសបូព៌្វរភា    ប្អូនផ្តាំបងថាឲ្យបងទៅ ៗ

ផ្គរពីឯលិចល្ងិចឆ្លើយទៀត ក្នុងទ្រូងបង្អៀតគគុកក្ដុលក្ដៅ
ឯជើងឆ្លើយឡើងដូចគេហៅ ឲ្យបងហើរទៅកាន់សារិកា ៗ
ផ្គរពីឯត្បូងឆ្លើយឡើងហើយ លាន់ឮល្វើយៗឆ្ងាយណាស់សា
ដូចយើងព្រាត់ប្រាស់ឆ្ងាយពីគ្នា កំព្រាតែឯងកណ្ដាលសល់ ៗ
ឱកម្មៗកាចក្រៃផល់ម៉្លេះ កម្មបេះកម្មតាំនាំមកផ្ដល់
ឲ្យកើតអំពើតែងអំពល់ ក្រហាយក្រហល់ខ្វល់ក្នុងចិត្ត ៗ
មិនទាន់រួមរ៉ានបានប៉ុន្មាន ទើបបានប្រាំពីរថ្ងៃនៅនិត្យ
ត្រូវស្ងួតឃ្លាតអ្នកវរមិត្រ ចុះកើតសុខចិត្តទៅត្រង់ណា ៗ
គឺកម្មឯងកាលពីជាតិមុន ធ្វើបុណ្យធ្វើបាបលាយផងគ្នា
បុណ្យនោះឲ្យបានស្រីសារិកា ឯបាបនោះណាឲ្យឃ្លាតឆ្ងាយៗ
ជាតិអើយជាតិនេះខ្ញុំមានកម្ម នៅព្រាំតែទុក្ខក្ដុកក្ដលកាយ
ជាតិក្រោយកុំឲ្យស្ងួនស្រណោយ កុំឲ្យព្រាត់ព្រោយដូច្នេះណា ៗ
ខ្ញុំអញអើយកើតទុក្ខធំ ប៉ុនភ្នំសង្កត់លើទ្រូង
វេទុក្ខផ្ទួនខ្ញុំម៉្លេះណា មិនជាបេះស្បើយស្ហើយត្រង់ណាៗ
យប់សោកនឹងជេកៗមិនលក់ ទឹកចំពុះសុខសព្វទិវា
ស្រក់តែទឹកភ្នែកគ្រប់វេលា ព្រួកសារិកាតែវតាមឆ្ងាយ ៗ

និងផ្កាដោយទឹកហូរមិនដល់ និងផ្កាដោយខ្យល់ៗផាត់ផាយ
ផ្កាដោយសត្វហើរៗព្រាត់ព្រាយ ទឹងតិចៗបាយផ្កាម្តេចបាន ៗ
សោកសោមតាំងតែកើតជាទុក្ខ អផ្សុកមិនមានហៅស្រាកស្រាន្ត
នឹកទៅសារិកាកែវកល្យាណ មិនមានល្ហុះលែងមួយវេលា ៗ
នឹងថ្លៃផងទំនងតាមសេចក្តី ពីស្រីសារិកាកែវកល្យាណ
តាំងពីសោកសោមតោមយៅរមាណសារិការក្រៀមប្រាណកើតទុក្ខក្រៃ ៗ
រឭករល្ហុងស្រក់ទឹកភ្នែក តឹងទ្រូងស្ទើរបែកតែសព្វថ្ងៃ
ឃើញសោកសារិកាផងដទៃ ស្រមៃថាជាសោមបណ្ឌិត ៗ
ដល់បែរប្រែមើលទៅឲ្យជាក់ មិនមានខ្លួនអ្នកប្រុសស្នេហ៍ស្និទ្ធ
កន្ទេងសង្រេងតែក្នុងចិត្ត គណិតអនេកតែម្នាក់ឯង ៗ
ខ្លួនអញអើយហៅកំព្រា ប្រាសព្រាត់ពីគ្នាពេញចម្បែង
ឃើញតែទីឋានជាកន្លែង ទីតែងជួបទំនុំគ្នា ៗ
គ្រង់នេះកាលប្អូននឹងអ្នកសោក ចូលដេកតាំងពីររួមវាស្នា
គ្រង់នេះកាលយើងទើបបានគ្នា បរហាសើបលេងជាសប្បាយ ៗ
គ្រង់នេះកាលយើងស៊ីទៀបទុំ លាជលាយទឹកឃ្មុំទំពាំងឡាយ
គ្រង់នេះកាលយើងបាននិយាយ ឥឡូវព្រាត់ព្រាយបាត់ទៅណា ៗ

ទុកម្មតើយកម្មសល់សែនកម្ម   ប្អូនត្រាំតែទុក្ខសព្វវេលា
ឃើញសេកប្រព័ត់លើវេហាស៍   ជួបជុំសស់គ្នាជាសប្បាយ ។
តេទិកទីត្រយ៉ឹងសត្វអកគៅ   អកឯកហើរទៅទំបានឆ្ងាយ
ជួបជុំកូនចៅផងទាំងឡាយ   មិនមានខ្វល់ខ្វាយព្រាត់ទៅណា ។
តែខ្លួនអញឯងមកនិរាស   ព្រាត់ប្រាសបែកចាកចេញពីគ្នា
ឈឺចិត្តខ្ញុំគិតគេក្ដុទា   កំព្រាតែឯងឯកណ្ដោនសល់ ។
ចេះតែផ្គម្ភផ្ទៃតែទុក្ខ   មិនមានសាន្តសុខក្នុងកាយកល
ឲ្យកើតគំពើតែឥតពល   ក្រហាយក្រហល់ក្នុងចិត្តា ។
ទុប្អូនញាប់ស៊ីអស់បំណី   ពីសេសពីស្រីគ្រាកាលជា
ពីនាក់ទីផ៍សេកជាសង្សារ   ឥឡូវទៅណាមិនឃើញមក ។
ប្អូនដេកម្នាក់ឯងតែនរងារ   គ្មានគ្នាទីផ៍កោនទុនអោបផ្ទក
ពីដើមមាសថ្ងៃថ្ងើមពន្លក   ក្មួកមកដេកជិតនិត្យកក់ក្ដៅ ។
លង់ល្ងុរគាគ្រាត្យសួរប្ដូរស្រម៉ាក់   ឮតែមាត់សត្វយំយប់ជ្រៅ
ស្រមៃហាក់ជួបអកសេកហៅ   ស្ដាប់ទៅមិនមែនពាក្យប្រុសទេ ។
លន្ទង់លនឿចតែក្នុងចិត្ត   អាណិតខ្លួនពោកមិនជួបគេ
ឲ្យកើតតែកម្មគ្មានទំនេរ   រំពារហាល់ក្នុងចិត្តា ។

អ្នកណាប្អូនទៅតែបីថ្ងៃ  នឹងវិលវិញមកតាប់ក៏
កន្លះទៅយូរច្រើនទិវា  យល់បងមានទៀតជាស្មៀតហើយៗ
ទេញខ្ញុំបងខ្លួនទៅឥសារ  ឥតការទៅទេណាខ្លួនអើយ
គេលោមបានខ្លួនទៅអស់ហើយ  វៀសពីកោះកើយទៅស្រុកបាត់ ។
គឺកម្មបុណ្យខ្លួនបានបំរះ  សង្សារគេផ្ដាសឲ្យព្រាយព្រាត់
បាបនោះមកផ្ដល់ឲ្យឆ្ងាយខ្ចាត់  បែកបាក់អ្នកបងសម្លាញ់ប្អូន ។
ឲ្យប្រាសឲ្យព្រាត់ពីខ្លួនទៅ  បាត់ពីលំនៅស្ងាត់ឈឹងសូន្យ
បុណ្យខ្លួនតិចណាស់មិនជួយប្អូន  ឲ្យប្រាសព្រាត់ព្រាយចេញពីអ្នក ។
មើលមេឃ ៗ មិនមកស្រទំ  ស្ដាប់សូរផ្គរដំឡើយឥតឈាក់
លាន់ឮល្វើយៗកៀនស្រោកដូចអ្នកស្រែកហៅប្អូនផងអើយៗ
មើលទៅពពកវៃឆ្ងាយ  ខ្យល់បក់ផាត់ផាយឆ្ងាយណាស់ហើយ
ប្អូនឈោងដៃតាមមិនដល់ឡើយ  ឆ្ងាយហើយឆ្ងាយហួសគិតឧបមា ។
ឲ្យឆ្ងាយវិងឆ្ងាយសល់សែនគិត  ឆ្ងាយចិត្តឆ្ងាយខ្លួនខ្លួនណាស់សា
ឆ្ងាយទីជំរកដេកផងគ្នា  ឆ្ងាយនេះហៅមហាសល់សែនឆ្ងាយៗ
ឲបានរួមជានទៅប៉ុន្មាន  ទើបបានតែត្រឹមប្រាំពីរថ្ងៃ
ត្រឹមតែឃ្លាតអ្នកថើមថ្ងៃ  ឲ្យតែស្រមៃឃើញមិនបាត់ ។

ប្អូនទំយំមើលទៅលើមេឃ   ឃើញគស់សត្វសេកហើរប្រាក់
ស្មានតែអ្នកថ្លៃថ្មើមប្រមាត់   ហើរកាត់មករកប្អូនឯកា ។
មើលទៅមិនមែនជាអ្នកសេក   ខុសគ្នាពន់ពេកប្លែកប្រកាយ
ស្មោស្មុកចំប្រប់មិនសប្បាយ   រើកយកក្នុងចិន្តា ។
ដេកយប់មមើតែសព្វថ្ងៃ   មមាលដូចថ្ងៃដេកជិតគ្នា
កម្មប្អូនឲ្យព្រាសសោកសង្សារ   ព្រាត់ព្រាយពីគ្នាទៅទិសឆ្ងាយ ។
ព្រាសអ្នកថាន់សេះទៅដូចេះ   ទុនប្អូនស្មើប្រេះញាក់ថ្មើមញាយ
ហាក់ឃើញថ្មី១ដិតទៅកាយ   ស្តាយអើយរឹងស្តាយពន់ពេកក្រៃ ។
ថ្លៃអើយអ្នកថ្លៃថ្មើមទឹមចិត្ត   មួលមួយជីវិតជួងហឫទ័យ
ស្ងួនស្លាប់ផងគ្នាសោះសង្ស័យ   អ្នកថ្លៃចោលប្អូនបាត់ទៅណា ។
ប្អូនផ្ញុំដោយទឹកហូរមិនដល់   ប្អូនផ្ញុំដោយខ្យល់វមិនជា
មិនចេះទីស្ថិតក្រុងណា   ផ្ញុំដោយពាក្យាហើរមិនដល់ ។
ទាល់សែនទាល់ពីកាលចិត្ត   ប្អូនតែងគិតស្មើរជាប់ខ្យល់
កើតទុក្ខធំណាស់ក្រាស់សែនសល់   ព្រោះទៅមិនដល់ដូចចិន្តា ។
សារិកាកែវកាលសោកសោមសត្វ   ព្រាសព្រាត់ពីខ្លួនទៅកាលណា
ចេះតែជាទុក្ខសព្វទិវា   មិនឲ្យលោះលាដល់មួយថ្ងៃ ។

ពីព្រេនសត្វសេកនិងសារិកា　　ធ្វើបុណ្យផងគ្នាជាបវិត្រ
បុណ្យនោះជួយជូនតែសត្វថ្ងៃ　　មិនឲ្យឃ្លាតឃ្លាទៅឋានឆ្ងាយៗ
យូរទៅសត្វសេកនិងសារិកា　　បានជួបជុំគ្នាជាសប្បាយ
រួមរួមនោរម្យតែសត្វកាយ　　បរហារស្រួលកាយជាសុខសាន្តៗ
ស្រេចហើយសត្វសេកនិងសារិកា　　ថ្លែងប្រាប់ទុក្ខគ្នាពីព្រាត់ប្រាណ
កើតទុក្ខក្សួនមួនមែនមាន　　ឥឡូវនេះបានស្បើយទុក្ខាៗ
និទានមុនមានមកពីព្រេន　　សម្ដែងសត្វសេកនិងសារិកា
នាមន័យខ្ញុំឈ្មោះអ្នកទកញ៉ា　　បញ្ញាធិបតីកែរិតគាប់ ៗ

= ចប់ =